Insert your school crest here

# *Tell Them From Me* student survey:

## Information and consent form for parents and carers

# ការស្ទង់មតិសិស្ស *Tell Them From Me* ៖

## ព័ត៌មាននិងក្រដាសទម្រង់បែបបទផ្តល់ការអនុញ្ញាតសម្រាប់មាតាបិតានិងអ្នកថែទាំ

ជម្រាបមកដល់មាតាបិតានិងអ្នកថែទាំ

នៅត្រីមាសនេះ សាលារៀនយើងនឹងចូលរួមក្នុងការស្ទង់មតិសិស្ស *Tell Them From Me (ប្រាប់គេពីខ្ញុំ)*។ ការស្ទង់មតិនេះនឹងផ្តល់ឲ្យយើងនូវមតិត្រឡប់ដ៏មានតម្លៃ អំពីអ្វីៗដែលជាការយល់ឃើញរបស់សិស្សអំពីជីវិតជាសិស្សសាលារៀន របៀបដែលសិស្សចូលរួមជាមួយសាលារៀន និងវិធីផ្សេងៗដែលគ្រូបង្រៀនធ្វើទំនាក់ទំនងជាមួយសិស្ស។

ការស្ទង់មតិនេះត្រូវបានចាត់ចែងដោយ The Learning Bar ដែលជាក្រុមហ៊ុនស្រាវជ្រាវឯករាជ្យមួយ និងដែលមានជំនាញនៅក្នុងការស្ទង់មតិនៅតាមសាលារៀន។

ព្រមជាមួយនឹងការផ្តល់ឲ្យសាលារៀននូវមតិត្រឡប់ពីសិស្សរបស់យើង ការស្ទង់មតិនេះមានគោលបំណងធំទូលាយមួយ។ វាផ្តល់ឲ្យ Department of Education តាមរយៈ Centre for Education Statistics and Evaluation នូវការយល់ដឹងអំពីសុខុមាលភាព និងការចូលរួមរបស់សិស្ស ព្រមទាំងការអនុវត្តការបង្រៀនដ៏មានប្រសិទ្ធភាពសម្រាប់ការកែលំអសាលារៀនជាបន្តទៅទៀត។ ការណ៍នេះត្រូវបានធ្វើឡើងតាមរយៈការប្រើទិន្នន័យដែលមិនប្រាប់ឲ្យដឹងនូវអត្តសញ្ញាណរបស់សិស្ស នៅទូទាំងរដ្ឋ NSW។

ការស្ទង់មតិនេះត្រូវបាន**លាក់ការសម្ងាត់** ហើយបុគ្គលិកសាលារៀននឹង**មិន**អាចស្គាល់ដឹងអត្តសញ្ញាណសិស្សណាមួយតាមរយៈចម្លើយរបស់ពួកគេបានឡើយ។

ដើម្បីធានាឱ្យបាននូវការលាក់ការសម្ងាត់ សិស្សដែលចូលរួមនឹងទទួលឈ្មោះប្រើប្រាស់(username)និងពាក្យសម្ងាត់ពិសេស។ ព័ត៌មានត្រូវបានរាយការណ៍តែនៅពេលណាដែលមានសិស្សចាប់ពីប្រាំនាក់ឡើងទៅឆ្លើយសំណួរណាមួយប៉ុណ្ណោះ។ ព័ត៌មានទាំងអស់នឹងត្រូវបានចាត់ចែងដោយយោងទៅតាមច្បាប់ឯកជនភាពដែលពាក់ព័ន្ធ។ ព័ត៌មានផ្ទាល់ខ្លួនរបស់សិស្សនឹង**មិន**ត្រូវបានបញ្ចេញដោយក្រសួងទៅឲ្យបុគ្គលឬស្ថាប័នផ្សេងទៀតណាមួយ ក្រៅតែពីតម្រូវដោយច្បាប់នោះឡើយ។ សិស្សនីមួយៗនឹងមិនត្រូវបានស្គាល់អត្តសញ្ញាណនៅក្នុងការបោះផ្សាយណាមួយទេ។

ការស្ទង់មតិនេះត្រូវបានធ្វើតាមអនឡាញ ដោយត្រូវការពេល 15 ទៅ 30 នាទី ហើយនឹងធ្វើទៅនៅឯសាលារៀនក្នុងអំឡុងម៉ោងសិក្សា។ យើងនឹងទទួលរបាយការណ៍មួយអំពីលទ្ធផលនៃការស្ទង់មតិរបស់សាលារៀនយើងនៅពេលដ៏ខ្លីបន្ទាប់ពីសិស្សរបស់យើងបំពេញការស្ទង់មតិនេះរួចរាល់ហើយ។

ការចូលរួមនៅក្នុងការស្ទង់មតិនេះគឺជាការ**ស្ម័គ្រចិត្ត**។ បើសំណួរស្ទង់មតិណាមួយធ្វើឲ្យកូនលោកអ្នកមានអារម្មណ៍មិនសប្បាយចិត្ត កូនលោកអ្នកអាចរំលងសំណួរនេះបាន ឬអាចសម្រេចចិត្តបញ្ឈប់ការស្ទង់មតិនេះនៅពេលណាមួយក៏បានដែរ។

បើលោកអ្នក**មិនចង់ឲ្យកូនលោកអ្នកចូលរួម**នៅក្នុងការស្ទង់មតិនេះទេ សូមបំពេញក្រដាសទម្រង់បែបបទដែលភ្ជាប់ជាមួយនេះ ហើយប្រគល់វាទៅឲ្យសាលារៀនវិញ មិនឲ្យហួសពីថ្ងៃទី delete and insert date of return

ព័ត៌មានបន្ថែមអំពីការស្ទង់មតិនិងការស្រាវជ្រាវ មានជាភាសាអង់គ្លេសនៅឯ education.nsw.gov.au/ttfm

delete and insert name of principal

នាយកសាលារៀន

delete and insert name of school

## *Tell Them From Me* Student Survey non-consent form

## ក្រដាសទម្រង់បែបបទមិនផ្ដល់ការអនុញ្ញាតសម្រាប់ការស្ទង់មតិសិស្ស *Tell Them From Me*

បើលោកអ្នក**មិនចង់ឲ្យ**កូនលោកអ្នកចូលរួមនៅក្នុងការស្ទង់មតិត្រឡប់របស់សិស្សនេះទេ សូមចុះហត្ថលេខាលើក្រដាសទម្រង់បែបបទនេះ ហើយប្រគល់វាទៅឲ្យសាលារៀនវិញ មិនឲ្យហួសពីថ្ងៃទី delete and insert date of return

**ខ្ញុំមិន**ផ្ដល់ការអនុញ្ញាតឲ្យកូនខ្ញុំចូលរួមនៅក្នុងការស្ទង់មតិសិស្ស ***ប្រាប់គេពីខ្ញុំ*** ឡើយ។

ឈ្មោះសិស្សទី 1

ថ្នាក់រៀនរបស់សិស្សទី 1

ឈ្មោះសិស្សទី 2

ថ្នាក់រៀនរបស់សិស្សទី 2

ឈ្មោះសិស្សទី 3

ថ្នាក់រៀនរបស់សិស្សទី 3

ឈ្មោះសិស្សទី 4

ថ្នាក់រៀនរបស់សិស្សទី 4

ឈ្មោះមាតាឬបិតា ឬអ្នកថែទាំ

ហត្ថលេខារបស់មាតាឬបិតា ឬអ្នកថែទាំ

ថ្ងៃទី